# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
រដ្ឋបាលខេត្តកណ្ដាល
លេខៈ ១៧៥...ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំយន្តការគាំទ្រការអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលខេត្តកណ្ដាល

## អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៦៣ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តកណ្ដាល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញប្រកាសលេខ ៤២៧៤ ប្រក. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការ នៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបធ្វើការងារ នៃការិយាល័យទាំងនោះ
- យោងតាមសេចក្តីណែនាំលេខ ០២៤សណន/គ.ជ.អ.ប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ របស់ គ.ជ.អ.ប ស្តីពីការរៀបចំយន្តការគាំទ្រការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមស្មារតីកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តកណ្ដាល នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលខេត្តកណ្ដាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យដំណើរការនូវ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តកណ្ដាល ដើម្បីអភិវឌ្ឍសមត្ថភាព រដ្ឋបាលខេត្តកណ្ដាល និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តកណ្ដាល។

**ប្រការ ២.-**

មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តកណ្ដាល រួមមានគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សមួយ និង ក្រុមការងារបច្ចេកទេសមួយជាជំនួយការ។

**ប្រការ ៣.-**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តកណ្តាលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **គីម រិទ្ធី** | អភិបាលរងខេត្ត | ប្រធាន |
| ២.ឯកឧត្តម | **ចយ សុចិន** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| ៣.លោកជំទាវ | **ហ៊ីន កុសនី** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| ៤.លោក | **ញឹម វណ្ណឌិន** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥.លោក | **អៀច សុវណ្ណវាសនា** | នាយករងទីចាត់ការធនធានមនុស្ស | សមាជិក |
| ៦.លោក | **យ៉ន តិរិន** | អនុប្រធានការិយាល័យកសាងសមត្ថភាព | លេខាធិការ |

**ប្រការ ៤.-**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មានតួនាទីដឹកនាំ សម្របសម្រួល តាម ដានត្រួតពិនិត្យនិងវាយតម្លៃ លើការងារអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល និង មន្ត្រីបុគ្គលិក នៅរដ្ឋបាលខេត្ត និងមានភារកិច្ចដូចខាងក្រោម៖

- ធានាឱ្យមានការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន
- ផ្តល់ការណែនាំ ពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- សម្របសម្រួលសកម្មភាពអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យ ផ្តល់យោបល់ និងឯកភាពលើឯកសារ និងរបាយការណ៍អំពីការអភិវឌ្ឍសមត្ថភាព នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- កៀរគរធនធានសម្រាប់គាំទ្រការងារអភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធានាថាការគ្រប់គ្រងហិរញ្ញវត្ថុរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត អនុវត្តបានត្រឹមត្រូវទៅ តាមបែបបទ និងនីតិវិធីដែលបានកំណត់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពនៃការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធានាឱ្យមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មានទីកន្លែងសមស្របសម្រាប់បំពេញការងារ មានឧបករណ៍ សម្ភារៈគ្រប់គ្រាន់សម្រាប់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន មានបន្ទប់ប្រជុំសមស្របសម្រាប់អនុវត្តសកម្មភាពនានា និងមានប្រព័ន្ធផ្តល់ព័ត៌មានទាន់ហេតុការណ៍ និងប្រព័ន្ធទុកដាក់តម្កល់ ឯកសារ។

**ប្រការ ៥.-**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មានរបៀបរបបការងារដូចខាងក្រោម ៖

- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្នុងការបំពេញការងាររបស់ខ្លួន
- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ត្រូវជួបប្រជុំយ៉ាងតិច០២ខែម្តង និងតាមការចាំបាច់ ដើម្បីតាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ដែលអាចកើតមាននៅក្នុងការអនុវត្តការងារពាក់ព័ន្ធការអភិវឌ្ឍសមត្ថភាព

- កូរ៉ុមនៃកិច្ចប្រជុំ ត្រូវមានលើសពីពាក់កណ្ដាលនៃសមាជិកគណៈកម្មាធិការទាំងមូល
- ប្រធានគណៈកម្មាធិការជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឱ្យសមាជិកណាមួយ ជាប្រធានស្ដីទី
- សេចក្ដីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្ដាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។ លេខាធិការមិនមានសិទ្ធិបោះឆ្នោតឡើយ
- ប្រធានគណៈកម្មាធិការ ត្រូវអញ្ជើញតំណាងក្រុមការងារបច្ចេកទេស ចូលរួមប្រជុំនៅគ្រប់កិច្ចប្រជុំ របស់ខ្លួន
- ប្រធានគណៈកម្មាធិការអាចអញ្ជើញប្រធានមន្ទីរ អង្គភាពជំនាញ តំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អ្នកផ្ដល់សេវាកម្មផ្នែកអភិវឌ្ឍន៍សមត្ថភាព និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ តាមការចាំបាច់
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការរបស់ គណៈកម្មាធិការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ការិយាល័យកសាងសមត្ថភាព នៃទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃសាលាខេត្ត ធ្វើជាសេនាធិការ ជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។

**ប្រការ ៦.-**

ក្រុមការងារបច្ចេកទេសរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមុស្សខេត្តកណ្ដាលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | លោក យ៉ាំ សារឹង | ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត |
| ២. | លោក ទូច គឹមឆាន | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពខេត្ត |
| ៣. | លោក បូ សារឿន | បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាខេត្ត |
| ៤. | លោក សៅ សារី | ទីប្រឹក្សាហិរញ្ញវត្ថុខេត្ត |
| ៥. | លោក ជ្រាយ ចំរើន | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត |
| ៦. | លោក វ៉ាន់ ម៉ូនីកា | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត |
| ៧. | លោក ទិត តូ | បុគ្គលិកព័ត៌មានវិទ្យាខេត្ត |
| ៨. | លោក សេត វាសនា | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពក្រុង ស្រុក |
| ៩. | លោកស្រី សូ ស៊ាងសុធារី | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពក្រុង ស្រុក |
| ១០. | លោកស្រី លឹម សុគន្ធារី | ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពក្រុង ស្រុក |
| ១១. | លោក នឿន ប៊ុនជា | បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក |
| ១២. | លោក ខឹម ប៊ុនណាត | បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាក្រុង ស្រុក |

**ប្រការ ៧.-**

ក្រុមការងារបច្ចេកទេសនេះ មានតួនាទីអភិវឌ្ឍសមត្ថភាពរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងគោលបំណង រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងរបៀបទំនាក់ទំនងជាមួយមណ្ឌល ជូនក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង អ្នក ពាក់ព័ន្ធនានា
- គាំទ្រដល់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងការបកស្រាយបំភ្លឺនានាពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
- ពង្រឹងសមត្ថភាពដល់ការិយាល័យកសាងសមត្ថភាព សំដៅធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាច គ្រប់គ្រង ចាត់ចែងកិច្ចការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និង មានលក្ខណៈឆ្លើយតប
- រៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ សម្រាប់អភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រី បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌល គណៈអភិបាល និងក្រុមប្រឹក្សាពិនិត្យ ផ្តល់យោបល់ និងអនុម័ត
- ធ្វើការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍ស្ថាប័ន ការរៀបចំនិងធ្វើបច្ចុប្បន្នភាពផែនការអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន ការរៀបចំតាក់តែង និងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័ន និង ការវាយតម្លៃ លទ្ធផលនៃការអភិវឌ្ឍស្ថាប័ន ស្របតាមខ្លឹមសារនៃសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នសម្រាប់ រដ្ឋបាលថ្នាក់ក្រោមជាតិ
- ធានាឱ្យមានការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ សមត្ថភាព រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលអំពីយេនឌ័រ បរិយាប័ន្ន និង សមធម៌ សង្គមប្រចាំឆ្នាំ ដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកផ្តល់សេវាកម្មផ្នែកអភិវឌ្ឍន៍សមត្ថភាពនៅក្នុងខេត្ត
- រៀបចំប្រព័ន្ធឆ្លើយតបទាន់ហេតុការណ៍ តាមរយៈការរៀបចំឱ្យមានប្រព័ន្ធទូរស័ព្ទ ទូរសារ និង អាស័យដ្ឋាន សារអេឡិចត្រូនិច ប្រព័ន្ធបណ្តាញសង្គម និងគេហទំព័រជាដើម សម្រាប់ទទួល និង ឆ្លើយតប ទៅនឹងសំណួរ ឬការស្នើសុំបំភ្លឺនានា ពីក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល អនុវត្ត និងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់យុទ្ធសាស្ត្រ និងគោលវិធីនៃការអភិវឌ្ឍសមត្ថភាព
- រៀបចំប្រព័ន្ធទុកដាក់ឯកសារទាំងឯកសារអេឡិចត្រូនិច និងឯកសារបោះពុម្ព ដែលពាក់ព័ន្ធទៅនឹង ការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួលជ្រើសរើសអង្គភាព ឬអ្នកផ្តល់សេវាកម្មអភិវឌ្ឍន៍សមត្ថភាព ក្នុងការផ្តល់កិច្ច អន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីកំណត់
- គាំទ្រដល់ការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ព្រមទាំងរៀបចំតារាងបូកសរុបទិន្នន័យ នៃការអភិវឌ្ឍ សមត្ថភាព
- ក្រៅពីតួនាទី ភារកិច្ចខាងលើ រដ្ឋបាលខេត្ត អាចបន្ថែមតួនាទី ភារកិច្ច តាមការចាំបាច់។

**ប្រការ ៨.-**

ក្រុមការងារបច្ចេកទេសត្រូវបំពេញការងារក្រោមការសម្របសម្រួលពីទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត និងមានរបៀបរបបការងារ ដូចខាងក្រោម ៖

គ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត ក្នុងការបំពេញការងាររបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត

- ក្រុមការងារបច្ចេកទេសត្រូវជួបប្រជុំយ៉ាងតិចមួយដង ក្នុងមួយខែ និងតាមការចាំបាច់ ក្រោមការសម្របសម្រួលរបស់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត
- គ្រប់កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេស ត្រូវមានរបៀបវារៈ និងកំណត់ហេតុ។ កំណត់ហេតុ កិច្ចប្រជុំត្រូវចម្លងជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌល ០១ច្បាប់
- សមាជិកក្រុមការងារម្នាក់ៗ ត្រូវរៀបចំផែនការការងារប្រចាំខែ និងរៀបចំរបាយការណ៍លទ្ធផលអនុវត្តការងារប្រចាំខែរបស់ខ្លួន
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមការងារបច្ចេកទេសត្រូវធ្វើទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងជាប្រចាំជាមួយការិយាល័យកសាងសមត្ថភាព
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្រុមការងារបច្ចេកទេសអាចស្នើសុំមតិយោបល់ពី គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស
- ក្រុមការងារបច្ចេកទេសត្រូវបែងចែកជាពីរក្រុម ដោយមួយក្រុមទទួលខុសត្រូវអភិវឌ្ឍន៍សមត្ថភាព ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និង មួយក្រុមទៀតទទួលខុសត្រូវ អភិវឌ្ឍន៍សមត្ថភាព គណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រុមការងារបច្ចេកទេសត្រូវរៀបចំឱ្យមានទីប្រឹក្សា ឬ បុគ្គលិករបស់មណ្ឌលប្រចាំការនៅរៀងរាល់ ម៉ោងធ្វើការងារ ដើម្បីទទួល និងឆ្លើយតបទៅនឹងសំណួរ ឬសំណើ សំណូមពរនានារបស់ ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឍការ និងវិសហមជ្ឈការ។

**ប្រការ ៩.-**

រាល់បទបញ្ញត្តិទាំងឡាយណារបស់រដ្ឋបាលខេត្តកណ្ដាល ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១០.-**

គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលខេត្ត។

**ប្រការ ១១.-**

ក្រុមប្រឹក្សាខេត្តកណ្ដាល គណៈអភិបាលខេត្តកណ្ដាល អង្គភាពនានាចំណុះខេត្តកណ្ដាល រដ្ឋបាលក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ក្នុងខេត្តកណ្ដាល មន្ទីរ អង្គភាពអង្គភាពជំនាញក្នុងខេត្ត និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដូចមានឈ្មោះក្នុងប្រការ៣ ប្រការ៦ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវ ទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ✎

កណ្ដាល ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៥

**អភិបាលខេត្ត**

ម៉ៅ ធនិន្ទណា

**ចម្លងជូន:**

-ក្រសួងមហាផ្ទៃ
-លេខាធិការដ្ឋាន គ.ជ.អ.ប
"ដើម្បីគោរពជូនជ្រាប"
-ដូចក្នុងប្រការ ១១
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ